# រឿងនាងរជ្ជុមាលា

( ចាក វិ. ខុ. )

( ការមិនប្រទូស្ត ជាសិរីក្នុងលោក )

កាល ព្រះសម្ពុទ្ធ គង់នៅក្នុងវត្តជេតពន នាក្រុងសាវត្ថី ។ កាលនោះមានកុមារីម្នាក់ជាកូនរបស់ទាសី អ្នកបំរើព្រាហ្មណ៍ម្នាក់ក្នុងស្រុក គយា ។

ឯនាងព្រាហ្មណី ជាភរិយារបស់ព្រាហ្មណ៍នោះ តាំងតែពីនាងកុមារី កូនទាសីរបស់ខ្លួនកើតឡើង មិនដែលបានសប្បាយចិត្តសោះ ។ តែឃើញកុមារីនោះពេលណា សេចក្តីក្រោធកើតមានពេលនោះ ។ ចំណែកនាងកុមារី ដល់ធំឡើង ក៏បំរើនាងព្រហ្មណី ជាមួយនឹងម្តាយ ប៉ុន្តែនាងពុំដែលបានសប្បាយចិត្តសោះ ព្រោះនាងព្រហ្មណី ចេះតែវាយតប់ ជេរប្រទេច ជានិច្ចរាល់ថ្ងៃ ។

ថ្ងៃមួយនាងកុមារីនោះ ទៅរកទាសីនាយសំពៅកោរសក់ឱ្យ លុះកោរហើយប្រញាប់ប្រញាល់ ត្រឡប់មកវិញ។ នាងព្រាហ្មណី ក្រឡេកឃើញក្បាលត្រងោលខឹងណាស់ ទើបយកខ្សែរ គោមួយចង្វាយ ស្ទុះទៅសំពងនាងកុមារីនោះ ហើយចង ក នាងដឹកយកទៅផ្ទះ ខ្សែរដែលចង ក នោះមិនឱ្យស្រាយឡើយ ទើបមនុស្សទាំងឡាយ ហៅនាងកុមារីនោះថា រជ្ជុមាលា ។ នាងរជ្ជុមាលានេះ បានជាចៅហ្វាយ ចេះតែស្អប់ឃើញមុខមិនបាន ព្រោះកាលពីជាតិមុន ក្នុងសាសនាព្រះពុទ្ធកស្សប នាងជាចៅហ្វាយរបស់នាងព្រាហ្មណី បានវាយទះតប់ទាសីរបស់ខ្លួនឥតត្រាប្រណីឡើយ បានជាពៀរនោះ តាមមកជាប់ បណ្តាលឱ្យនាងព្រាហ្មណីជេរប្រទេចទះតប់ខ្លួនវិញ ។ ឯនាងរជ្ជុមាលានេះ ជាស្រ្តីមានចិត្តធ្ងន់បំផុត មិនដែលខឹងតប ដោយពាក្យសំដី ឬដោយអាការៈណាមួយ ចំពោះនាងព្រាហ្មណីជាចៅហ្វាយឡើយ ។

ថ្ងៃមួយព្រះសម្ពុទ្ធបរមគ្រូ ទ្រង់ប្រមើលមើលនិស្ស័យសត្វ បានជ្រាបថានាងរជ្ជុមាលា ជាស្រ្តីមាននិស្ស័យខ្ពស់ ត្រូវបានសម្រេចដល់សោតា ។ លុះទ្រង់ជ្រាបដូច្នេះហើយ ពេលថ្ងៃរសៀល ក៏និមន្តទៅក្នុងព្រៃ ក្រោមដើមឈើមួយដើមក្បែរភូមិនាងព្រាហ្មណី នោះ ។ ឯនាងរជ្ជុមាលា កាលបើចៅហ្វាយចេះតែធ្វើបាបខ្លាំងដូច្នេះនាងព្រួយចិត្តខ្លាំងណាស់ ក៏កាន់ក្អមធ្វើជាទៅដងទឹក ហើយលួចរត់ចូលទៅក្នុងព្រៃ ដើម្បីចងក ។ ទៅដល់ឃើញដើមឈើធំមួយ ក៏ឡើងទៅខាងលើយកខ្សែរម្ខា

ងចងក ខ្សែរម្នាងចងភ្ជាប់ទៅមែកឈើ បំរុងនឹងលោតសម្លាប់ខ្លួន ។ ស្រាប់តែឃើញព្រះសម្ពុទ្ធ គង់ក្រោមម្លប់ឈើមួយដើមក្បែរឈើរដែលខ្លួនឡើងនោះ ។ សេចក្តីជ្រះថ្លាក៏កើតឡើង ទើបស្រាយខ្សែរអំពីក ហើយចុះទៅថ្វាយបង្គំព្រះសម្ពុទ្ធ ព្រះសម្ពុទ្ធ ទ្រង់ត្រាស់សួរថា នាងមកមានការអ្វី ? ។ នាងវជ្ជមាលា បានថ្លែងប្រវត្តិរបស់ខ្លួន ថ្វាយព្រះសម្ពុទ្ធជាម្ចាស់ តាំងពីដើមដល់ចប់ ។ លុះចប់ហើយព្រះសម្ពុទ្ធ ទ្រង់សំដែងអនុបុព្វិកថា ឱ្យនាងស្តាប់ ។ នាងខំផ្ចង់ស្មារតី ស្តាប់ដរាបដល់ចប់ ក៏បានសម្រេចសោតាបត្តិផល ហើយថ្វាយបង្គំលា ព្រះសម្ពុទ្ធ រួចកណ្តៀតក្អមដងទឹកទៅផ្ទះវិញ ។

កាលនោះព្រាហ្មណ៍ ជាស្វាមីរបស់នាងព្រាហ្មណី កំពុងអង្គុយនៅមាត់ទ្វារ បានឃើញនាងវជ្ជមាលា មានទឹកមុខស្រស់បស់ជាងសព្វដង ក៏សួរថា នាងទៅណាយូរម្ល៉េះ ? មកវិញស្រាប់តែញញឹមញញែម ?  នាងប្រាប់ចៅហ្វាយថា ខ្ញុំបានជួបនឹងព្រះពុទ្ធ ព្រះអង្គគង់នៅក្នុងដងព្រៃភូមិ ខ្ញុំស្តាប់ធម៌ព្រះអង្គបានជាយូរ ក្រមក ។ មនុស្សទាំងឡាយក្នុងស្រុកគយា បានឮថា ព្រះដ៏មានព្រះភាគនិមន្តមក ក៏នាំគ្នាទៅបបួលនាងព្រាហ្មណី ទៅថ្វាយបង្គំព្រះសម្ពុទ្ធ ។ កាលបើមហាជនទៅជួបជុំគ្នាហើយ ព្រះសម្ពុទ្ធទ្រង់សំដែងអតីតនិទាន របស់នាងព្រាហ្មណីនិងនាងវជ្ជមាលា ឱ្យមហាជនបានដឹង ។ លុះចប់ហើយនាងព្រហ្មណីនិងស្វាមីរបស់នាងព្រមទាំងមហាជន ដែលទៅស្តាប់ព្រះធម៌ទាំងប៉ុន្មាន ក៏ដល់នូវត្រៃសរណគមន៍ខ្លះ បានរក្សាសីលប្រាំខ្លះ ។

ចាប់ពីថ្ងៃនោះមក នាងព្រាហ្មណីនិងនាងវជ្ជមាលា បានរាប់អានគ្នាដូចបងប្អូនបង្កើត ដរាបអស់ជីវិត ។ ឯនាងវជ្ជមាលា លុះធ្វើមរណកាលទៅ បានទៅកើតក្នុងស្ថានត្រៃតឹង្ស សោយទិព្វសម្បត្តិជាសុខក្សេមក្សាន្ត ។

វាយអត្ថបទដោយ ខ្ញុំព្រះករុណា ខ្ញុំបាទ យ៉ែម ភិរុណ។ ដកស្រង់ចេញប្រពីជុំនិទានជាតកភាគ១ របស់ព្រះបាឡាត់ឧត្តមលិខិត សុង ស៊ីវ សិទ្ធត្ថោ គ្រូបង្រៀនបាលីនៅវត្តលង្កា រាជធានីភ្នំពេញ ។ អរព្រះគុណព្រះភិក្ខុ សិរីបញ្ញោ ហ៊ុល សុខារ៉ា ព្រះគ្រូចៅអធិការ វត្តកល្យាណមិត្តខ្សាច់ពោយនិងលោកអាចារ្យ ចយ ធិន
សូមអស់លោកអ្នកអនុមោទនា !ចប់